# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ធនាគារជាតិ នៃ កម្ពុជា

## សេចក្តីថ្លែងការណ៍រួម
## រវាង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ធនាគារជាតិនៃកម្ពុជា

នាពេលថ្មីនេះ រាជរដ្ឋាភិបាលបានសង្កេតឃើញថា នៅតាមបណ្តាខេត្តមួយចំនួននៃព្រះរាជាណាចក្រកម្ពុជា បានទទួលរងគ្រោះទឹកជំនន់ដែលអាចធ្វើឲ្យប៉ះពាល់ដល់ហេដ្ឋារចនាសម្ព័ន្ធទូទៅ ជាពិសេសផលរបរកសិកម្មរបស់ប្រជាកសិករ។ ដើម្បីសម្រួលដល់ការប្រឈមផ្នែកហិរញ្ញវត្ថុដែលអាចកើតមានពីគ្រោះទឹកជំនន់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ធនាគារជាតិនៃកម្ពុជា សូមអំពាវនាវនិងលើកទឹកចិត្តចំពោះគ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ សូម៖

១. បន្តផ្តល់ឥណទានដោយប្រុងប្រយ័ត្ន និងមានយន្តការដោះស្រាយទន់ភ្លន់ចំពោះអតិថិជនដែលរងផលប៉ះពាល់ពីគ្រោះទឹកជំនន់ជាក់ស្តែង ដើម្បីរក្សាស្ថិរភាពនិងភាពរឹងមាំរបស់វិស័យហិរញ្ញវត្ថុ

២. បន្តពិនិត្យ និងវាយតម្លៃលទ្ធភាពសងរបស់ប្រជាកសិករដែលបានរងផលប៉ះពាល់ពីគ្រោះទឹកជំនន់ សម្រាប់ជាមូលដ្ឋានក្នុងការបន្ធូរបន្ថយរយៈពេលសង បន្ថយអត្រាការប្រាក់ ឬ មិនយកការប្រាក់ក្នុងរយៈពេលណាមួយ និងមិនត្រូវរឹបអូសទ្រព្យសម្បត្តិរបស់ប្រជាកសិករ ព្រមទាំងផ្តល់ដំណោះស្រាយសមស្របផ្សេងៗ និង

៣. បន្តតាមដានស្ថានភាព និងផលប៉ះពាល់នៃគ្រោះទឹកជំនន់លើប្រជាកសិករ និងផ្តល់ការគាំទ្រចាំបាច់ស្របតាមកាលៈទេសៈជាក់ស្តែង។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ធនាគារជាតិនៃកម្ពុជា សង្ឃឹមនិងជឿជាក់ថា គ្រឹះស្ថានធនាគារនិងមីក្រូហិរញ្ញវត្ថុ អាជ្ញាធរមូលដ្ឋាន និងដៃគូពាក់ព័ន្ធទាំងអស់ នឹងចូលរួមសហការក្នុងការជួយសម្រាលទុក្ខលំបាក និងសម្រាលសម្ពាធហិរញ្ញវត្ថុរបស់ប្រជាកសិករដែលបានទទួលរងផលប៉ះពាល់ពីគ្រោះទឹកជំនន់ជាក់ស្តែង។

ថ្ងៃសុក្រ ១៣កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៨